# សិក្ខាសាលាស្រាវជ្រាវ ស្តីពី
# «មូលដ្ឋានគ្រឹះនៃការស្រាវជ្រាវ»

សិល្បៈខ្មែរអមតៈ
មជ្ឈមណ្ឌលបេតិកភណ្ឌ

## អំពីសិក្ខាសាលាស្រាវជ្រាវ

ក្រោមកម្មវិធីចំណេះដឹង បណ្តាញ និងគោលនយោបាយ របស់អង្គការសិល្បៈខ្មែរអមតៈ មជ្ឈមណ្ឌលបេតិកភណ្ឌ នឹងរៀបចំសិក្ខាសាលាស្រាវជ្រាវមួយ ស្តីពី «មូលដ្ឋានគ្រឹះនៃកាស្រាវជ្រាវ» ដល់សិល្បករ អ្នកបម្រើការងារក្នុងវិស័យសិល្បៈនិងវប្បធម៌ ព្រមទាំងសិស្ស និងនិស្សិត **នៅថ្ងៃទី ៨ និង ៩ ខែមិថុនា ឆ្នាំ ២០១៩** នៅមជ្ឈមណ្ឌលបេតិកភណ្ឌ ក្រុងសៀមរាប។

សិក្ខាសាលានេះ មានគោលបំណងជួយសិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ សិស្ស និងនិស្សិតឱ្យទទួលបានចំណេះដឹងជាមូលដ្ឋាននៃការស្រាវជ្រាវ ដើម្បីចូលរួមធ្វើការសិក្សាស្រាវជ្រាវលើវិស័យសិល្បៈ និងវប្បធម៌។

ក្តីរំពឹងរបស់សិក្ខាសាលាស្រាវជ្រាវ សិក្ខាកាមទាំងអស់ នឹងទទួលបាន៖

- ចំណេះដឹងមូលដ្ឋាននៃការស្រាវជ្រាវ
- ចំណេះដឹងក្នុងការប្រមូលព័ត៌មានតាមរយៈការសំភាសន៍
- ចំណេះដឹងក្នុងការធ្វើរបាយការណ៍នៃការស្រាវជ្រាវ

នៅក្នុងយុទ្ធសាស្រ្តរយៈពេល ៥ ឆ្នាំរបស់យើង (២០១៧-២០២១) ក៏បានបញ្ជាក់ពីការអភិវឌ្ឍភាពច្នៃប្រឌិត, ការតស៊ូមតិ, និងការបង្កើតថ្មីផងដែរ។ តួនាទីរបស់ពួកយើង គឺជួយជំរុញឲ្យសិល្បករអាចបង្ហាញ និងផ្សារភ្ជាប់ខ្លួនគេជាមួយនឹងសង្គម, ដើម្បីចូលរួមទាំងអស់គ្នាក្នុងការបង្កើតឲ្យចេញជាលទ្ធផលវិជ្ជមានមួយសម្រាប់ប្រទេសកម្ពុជាយើងតាមរយៈសិល្បៈ។ ដោយយល់ឃើញថា សិល្បករកំពុងតែចូលរួមយ៉ាងសំខាន់ក្នុងវិស័យសិល្បៈ និងវប្បធម៌ សិល្បករចាំបាច់ទទួលបានឱកាសស្វែងយល់បន្ថែមពីជំនាញគ្រឹះសំខាន់ៗមួយចំនួនអំពីការស្រាវជ្រាវ ដើម្បីឈានទៅដល់មានជំនាញក្នុងការសរសេរ ចងក្រង ប្រវត្តិស្នាដៃ ការអង្កេត ឬការអភិវឌ្ឍនៃទម្រង់សិល្បៈណាមួយជាដើម។

## អត្ថប្រយោជន៍

- ឱកាសអនុវត្តផ្ទាល់ជាមួយគ្រូបង្វឹក
- ចំពោះសិក្ខាកាម មកពីចម្ងាយ ដូចជាខេត្តក្រុងផ្សេងៗ៖
    - *ថ្ងៃទី ៧ ខែមិថុនា ជាថ្ងៃធ្វើដំណើរមកកាន់សៀមរាប និងថ្ងៃទី ១០ ខែមិថុនា ជាថ្ងៃធ្វើដំណើរត្រឡប់ទៅគេហដ្ឋានវិញ។*

- *ការស្នាក់, ការហូបចុក និងការធ្វើដំណើរ នឹងត្រូវបានរៀបចំជូន។*

- អ្នកចូលរួមក្នុងសិក្ខាសាលាទាំងអស់ នឹងមានរៀបចំអាហារថ្ងៃត្រង់ជូន។
- ឱកាសចូលរួមក្នុងបណ្តាញជាមួយអ្នកមានចំណង់ចំណូលចិត្តទាក់ទងនឹងការស្រាវជ្រាវ ជាពិសេសនៅក្នុងវិស័យសិល្បៈ និងវប្បធម៌

## របៀបដាក់ពាក្យ

- ចូលទៅក្នុង <u>តំណភ្ជាប់</u> នេះ ដើម្បីទាញយកពាក្យស្នើសុំចូលរួមក្នុងសិក្ខាសាលា
- បំពេញពាក្យស្នើសុំចូលរួមក្នុងសិក្ខាសាលានេះ តាមតំណភ្ជាប់នេះ ឬផ្ញើចំណាប់អារម្មណ៍របស់អ្នក ដោយបំពេញព័ត៌មានសំខាន់ៗ (អាចបំពេញដោយកុំព្យូទ័រ ឬដៃ)
  មកកាន់ ជឿន សុជាតា តាមរយៈអ៊ីម៉ែល socheata@cambodianlivingarts.org មិនឱ្យលើសពីថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០១៩ ឡើយ។

## លក្ខខណ្ឌជ្រើសរើស

- មានចំណាប់អារម្មណ៍អំពីការស្រាវជ្រាវ
- ជាសិល្បករ អ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ សិស្សនិស្សិត
- មានពេលវេលាចូលរួមពេញលេញ រយៈពេលពីរថ្ងៃ ដោយគ្មានការរំខាន

## កាលបរិច្ឆេទសំខាន់ៗ

- ចាប់ផ្តើមទទួលពាក្យ៖ ថ្ងៃទី១ ខែមេសា ដល់ ១៥ ខែឧសភា ឆ្នាំ ២០១៩
- ប្រកាសឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើស៖ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៩

## កំណត់ចំណាំ

សិក្ខាសាលានេះទទួលចុះឈ្មោះសិក្ខាកាមត្រឹម ២០ នាក់ប៉ុណ្ណោះ